multicultural health communication

Khmer
[DOH-7115]

# ជម្ងឺ គ្រីពតូស្ព័ររីឌីអូហ្ស៊ីស (Cryptosporidiosis)

# Cryptosporidiosis

## តើជម្ងឺ cryptosporidiasis ជាអ្វី ?

- ជម្ងឺ cryptosporidiosis ជាជម្ងឺរាកមួយប្រភេទបង្កឡើងដោយប៉ារ៉ាស៊ីតឈ្មោះ Cryptosporidium ដែលយាយីពោះវៀន ។
- ការឆ្លងមេរោគ cryptosporidium ត្រូវគេរាយការណ៍ថា កើតមានមនុស្ស និងកសិដ្ឋានមួយចំនួនផ្សេងៗគ្នា, សត្វចិញ្ចឹម លេង និងពពួកសត្វក្នុងស្រុក។
- ទោះបីជាមានពួក cryptosporidium ច្រើនប្រភេទផ្សេងៗគ្នាក៏ដោយ ក៏មានតែមួយប្រភេទប៉ុណ្ណោះគឺ crytosporidium parvum ត្រូវបានគេគិតថាបង្កឲ្យមានការឆ្លងចំពោះមនុស្ស ។
- ក្រសួងសុខាភិបាលរដ្ឋ NSW បានទទួលដំណឹងអំពីជម្ងឺ cryptosporidisis តាំងពីឆ្នាំ១៩៩៦ម្ល៉េះ។ ចំនួនករណីជម្ងឺនេះច្រើនកើនឡើងនៅរដូវក្តៅនៅរដ្ឋ NSW ។

## តើជម្ងឺនេះឆ្លងរាលដាលយ៉ាងដូចម្តេច ?

- មេរោគ cryptosporidium មានវត្តមានក្នុងលាមករបស់មនុស្សនិងសត្វដែលមានរោគហើយឆ្លងតាមរយៈការលេបចូលតាមមាត់នូវលាមកដែលមានមេរោគ ។
- ជម្ងឺនេះឆ្លងបន្តនៅពេលដែលមានការលេបទំពារប៉ារ៉ាស៊ីតនេះ។
- ការចំលងភាគច្រើនកើតឡើងតាមរយៈ ៖
    - ការប៉ះពាល់រវាងនុស្សម្នាក់និងមនុស្ស ជាពិសេសក្នុងគ្រួសារ និងក្នុងចំណោមក្មេងតូចៗ (ឧទាហរណ៍ មណ្ឌលថែរក្សាកូនក្មេង)។
    - ការទទួលទានទឹកដែលមានមេរោគ
    - ហែលទឹកក្នុងអាងហែលទឹកដែលមានមេរោគ
    - ចំណីអាហារ (ក្នុងករណីកំរ)
    - ប៉ះពាល់សត្វដែលមានផ្ទុកមេរោគ
    - សកម្មភាពផ្លូវភេទដែលពាក់ព័ន្ធនឹងការប៉ះពាល់ជាមួយលាមក
- មនុស្សដែលងាយចំលងមេរោគខ្លាំងបំផុតនៅពេលដែលពួកគេមានជម្ងឺរាក។ យ៉ាងណាមិញ ប៉ារ៉ាស៊ីតនៅតែអាចបញ្ចេញមកក្រៅ ក្នុងរយៈពេលជាច្រើនសប្តាហ៍ បើទុកណាជារោគសញ្ញាបានបាត់អស់ក្តី។

## តើមានរោគសញ្ញាអ្វីខ្លះ ?

- រោគសញ្ញានៃជម្ងឺ cryptosporidiosis ដែលកើតមានញឹកញាប់ គឺ រាកសុទ្ធតែទឹក, ចុកពោះ, ក្តៅខ្លួន, ក្អួត និងចង្អោរ ។ រោគសញ្ញាទាំងនេះអាចបណ្តាលឲ្យស្រកទម្ងន់ និង បាត់បង់ជាតិទឹក ។



NSW GOVERNMENT Health

- បណ្ដាសញ្ញាដំបូងនៃជំងឺនេះលេចឡើងក្នុងរវាង ១-១២ ថ្ងៃ (ជាមធ្យម ៧ ថ្ងៃ) បន្ទាប់ពីជនណាម្នាក់បានឆ្លងមេរោគ ។
- ក្នុងករណីខ្លះពុំមានចេញជារោគសញ្ញាអ្វីទាំងអស់ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ជនទាំងនោះ នៅតែអាចចំលងជម្ងឺទៅអ្នកផ្សេងទៀតបានដែរ។
- មនុស្សដែលមានសុខភាពល្អ ភាគច្រើននឹងជាសះស្បើយឡើងវិញ ក្នុងរវាងពេលមិនដល់ ២ សប្ដាហ៍ផង។
- មនុស្សដែលមានប្រព័ន្ធការពាររោគចុះខ្សោយ អាចមានរោគសញ្ញាច្រើនជាងនេះ ដែលអាចបិតថេរអស់ពេលជាច្រើនសប្ដាហ៍ ។

## តើគេធ្វើរោគវិនិច្ឆ័យ និងព្យាបាលជម្ងឺនេះយ៉ាងដូចម្ដេច ?

- បើសិនលោកអ្នកមានរាករូស គេមានមធ្យោបាយតែមួយគត់ដើម្បីឲ្យដឹង គឺទៅជួបវេជ្ជបណ្ឌិត និងយកលាមកទៅពិនិត្យ បើសិនការរាកនេះ បង្កឡើងដោយ cryptosporidiosis នោះ។
- ការទទួលទានទឹកឲ្យបានគ្រប់គ្រាន់មានសារសំខាន់ណាស់ចំពោះអ្នកមានជម្ងឺរាក ដើម្បីជៀសវាងកង្វះជាតិទឹក ។
- គេពុំមានការព្យាបាលជាក់លាក់ចំពោះជម្ងឺ cryptosporidiosis ទេ។

## តើគេបង្ការជម្ងឺនេះយ៉ាងដូចម្ដេច ?

ដើម្បីជៀសវាងការកើតជម្ងឺ cryptosporidiosis ត្រូវ ៖

- លាងដៃជានិច្ចជាកាលជាមួយសាប៊ូនឹងទឹកម៉ាស៊ីនឲ្យបានស្អាតក្រោយពេលចេញពីបង្គន់, ប៉ះពាល់សត្វពាហនៈ,ផ្លាស់ប្ដូរកន្ទប ឬ ធ្វើការក្នុងសួនច្បារ និងមុនពេលរៀបចំម្ហូបអាហារនិងភេសជ្ជៈ។
- មិនត្រូវទទួលទានទឹកដែលមិនមានការសម្លាប់មេរោគទេ (ឧទាហរណ៍ ទឹកស្ទឹង/ទន្លេ, អូរ, បឹង ,និងត្រពាំង)។ ការដាំទឹកដែលបានមកពីប្រភពទាំងនេះឲ្យពុះ ឲ្យបានមួយនាទីនឹងអាចសំលាប់មេរោគបានដោយរួមទាំងមេរោគនៃជម្ងឺ cryptosporidiosis ផង។

ដើម្បីជៀសវាងការឆ្លងរាលដាលនៃជម្ងឺ Cryptosporidiosis :

- កុំឲ្យក្មេងតូចៗដែលមានជម្ងឺរាករូសទៅសាលា, មជ្ឈមណ្ឌលថែរក្សាក្មេង ឬ លេងជាក្រុមរហូតដល់ជម្ងឺរារូសបាត់ទាំងស្រុង។
- អ្នករៀបចំម្ហូបអាហារ, អ្នកថែទាំក្មេង និង បុគ្គលិកថែទាំសុខភាពដែលមានជម្ងឺ cryptosporidiosis មិនគួរ ធ្វើការទេរហូតទាល់តែជម្ងឺរាករូសបាត់ទាំងស្រុង ។
- ក្រោយពីយ៉ាងហោចណាស់ក៏មួយអាទិត្យដែរ បន្ទាប់ពីជម្ងឺរាកនេះបានជាសះស្បើយ លោកអ្នកមិនត្រូវ : ប្រើអាងហែលទឹក ឬក៏កន្លែងមុជទឹកកំសាន្តផ្សេងៗទៀតដែរ, ឬក៏ប្រើប្រាស់ស្រោមពូក, ខ្នើយ ឬកន្សែងពោះគោរួមជាមួយអ្នកផ្សេងទៀត។

**ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណ: (Public Health) នៅក្នុងរដ្ឋ NSW**



**1300 066 055** www.health.nsw.gov.au